**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

*ថ្ងៃពុធ ១៤ កើត ខែផល្គុន ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥*
*រាជធានីភ្នំពេញ, ថ្ងៃទី ១៦ ខែមីនា ឆ្នាំ២០២២*

# សេចក្តីប្រកាសព័ត៌មាន
## ស្តីពីពិធីចុះហត្ថលេខា
## លើអនុស្សរណៈនៃការយោគយល់គ្នាលើកិច្ចសហប្រតិបត្តិការក្នុងវិស័យគ្រប់គ្រងមុខងារសាធារណៈ រវាងក្រសួងមុខងារសាធារណៈ នៃព្រះរាជាណាចក្រកម្ពុជា និង រដ្ឋបាលមុខងារសាធារណៈជាតិនៃសាធារណរដ្ឋប្រជាមានិតចិន

នាព្រឹកថ្ងៃទី ១៦ ខែមីនា ឆ្នាំ២០២២, នៅទីស្តីការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងឯកឧត្តម **ជិន ស៊ី** (CHEN Xi) សមាជិកការិយាល័យនយោបាយ និងជាប្រធានគណៈចាត់តាំងមជ្ឈឹមបក្សកុម្មុយនីស្តចិន បានចូលរួមជាសក្ខីភាពដ៏ខ្ពង់ខ្ពស់ក្នុងពិធីចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នាលើ **"កិច្ចសហប្រតិបត្តិការក្នុងវិស័យគ្រប់គ្រងមុខងារសាធារណៈ"** តាមរយៈប្រព័ន្ធអនឡាញ រវាងក្រសួងមុខងារសាធារណៈនៃព្រះរាជាណាចក្រកម្ពុជា តំណាងដោយឯកឧត្តម **ប្រាំ សុខា** រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋបាលមុខងារសាធារណៈជាតិ នៃសាធារណរដ្ឋប្រជាមានិតចិន តំណាងដោយឯកឧត្តម **ហ្វូ ស៊ីងហ្គោ** (FU Xingguo) ប្រធានរដ្ឋបាលមុខងារសាធារណៈជាតិ នៃសាធារណរដ្ឋប្រជាមានិតចិន ។

**ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** បានសម្តែងនូវក្តីសោមនស្សរីករាយ និងបានលើកឡើងថា ពិធីចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នានេះ ពិតជាមានសារៈសំខាន់សម្រាប់ ទំនាក់ទំនងកិច្ចសហប្រតិបត្តិការទ្វេភាគី លើវិស័យមុខងារសាធារណៈ កម្ពុជា-ចិន ដើម្បីពង្រឹង និងរក្សាឲ្យបាននូវមុខងារសាធារណៈប្រកបដោយគុណភាព ប្រសិទ្ធភាព ប្រសិទ្ធផល និងផ្តោតប្រជាជនជាស្នូល ។ ពិធីចុះហត្ថលេខានាពេលនេះ បានឆ្លុះបញ្ចាំងពីគិតគូរច្បាស់លាស់ និងកិច្ចសហប្រតិបត្តិការទ្វេភាគីរវាងប្រទេសទាំងពីរនាពេលកន្លងមក តាមរយៈមិត្តភាពស្អិតរម្មួត, សាមគ្គីភាព និងភាពរឹងមាំនៃទំនាក់ទំនងទ្វេភាគី កម្ពុជា-ចិន ដែលបានរួមចំណែកក្នុងការជំរុញ និងទំនាក់ទំនងស៊ីជម្រៅរវាងប្រទេសទាំងពីរ ដោយប្រែក្លាយពីភាពជាដៃគូយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយមកជាមិត្តភាពដែកថែប និងសហគមន៍វាសនារួម កម្ពុជា-ចិន សំដៅអភិវឌ្ឍន៍លើគ្រប់វិស័យ ដើម្បីជំរុញការលើកកម្ពស់ជីវភាព និងសុខមាលភាពប្រជាជននៃប្រទេសទាំងពីរ ក្នុងកាលៈទេសៈនៃការរីករាលដាលនៃជំងឺកូវីឌ-១៩ ។

ឆ្លៀតក្នុងឱកាសនោះ, **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** ក៏បានថ្លែងអំណរគុណចំពោះឯកឧត្តម **ជីន ស៊ី** (CHEN Xi) និងរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតចិន នាពេលកន្លងមកផងដែរដែលបាន÷ ១. ដើរតួជាបង្អែក

យុទ្ធសាស្ត្រក្នុងការផ្គត់ផ្គង់វ៉ាក់សាំងកូវីដ-១៩, ២. ផ្តល់នូវជំនួយឧបត្ថម្ភផ្សេងៗក្នុងកិច្ចប្រឹងប្រែងប្រយុទ្ធនឹងជំងឺកូវីដ-១៩, ៣. ការចុះហត្ថលេខាលើកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីទ្វេភាគី កម្ពុជា-ចិន ដែលបើកច្រកកាន់តែទូលាយសម្រាប់ការផ្លាស់ប្តូរពាណិជ្ជកម្ម និងទីផ្សារសម្រាប់កសិផលកម្ពុជា និងព្រមទាំង ៤. បានបន្តផ្តល់នូវហិរញ្ញប្បទានឥតសំណង និងជំនួយបច្ចេកទេសសម្រាប់ការអភិវឌ្ឍសង្គម និងសេដ្ឋកិច្ចកម្ពុជា ទោះជាស្ថិតក្នុងកាលៈទេសៈដ៏លំបាកនៃការប្រឈមនឹងការរីករាលដាលជាសកលនៃជំងឺកូវីដ-១៩ ។

**ឯកឧត្តម ជឺន ស៊ី** (CHEN Xi) សមាជិកការិយាល័យនយោបាយ និងជាប្រធានគណៈចាត់តាំងមជ្ឈឹមបក្សកុម្មុយនីស្តចិន បានថ្លែងអំណរគុណ និងឯកភាពទាំងស្រុងចំពោះការលើកឡើងរបស់**ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** អំពីទំនាក់ទំនងដ៏រឹងមាំរវាង កម្ពុជា- ចិន និងប្តេជ្ញាបន្តជាសកម្ម និងភាគីចិនក៏នឹងត្រៀមខ្លួនជានិច្ចដើម្បីបន្តសហការជាមួយកម្ពុជា ទាំងក្នុងក្របខ័ណ្ឌតំបន់ និងនៅលើឆាកអន្តរជាតិ ក្នុងការរួមចំណែកពង្រឹងទំនាក់ទំនងទ្វេភាគី កម្ពុជា- ចិន ឱ្យកាន់តែល្អប្រសើរថែមទៀត ។

ចុងទីបញ្ចប់នៃពិធី, ភាគីទាំងពីរ តំណាងដោយ ឯកឧត្តម **ព្រុំ សុខា** រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈកម្ពុជា និង ឯកឧត្តម **ហ្វូ ស៊ីងហ្គោ** (FU Xingguo) ប្រធានរដ្ឋបាលមុខងារសាធារណៈជាតិនៃសាធារណរដ្ឋប្រជាមានិតចិន បានចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នា លើកិច្ចសហប្រតិបត្តិការក្នុងវិស័យគ្រប់គ្រងមុខងារសាធារណៈ ដែលជាការបើកទំព័រថ្មីនៃកិច្ចសហប្រតិបត្តិការទ្វេភាគីក្នុងវិស័យមុខងារសាធារណៈរវាងប្រទេសទាំងពីរ កម្ពុជា- ចិន ៕